# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបើកការអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅ
# ភ្នំពេញថ្មី ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០
## បើកទ្វារដើម្បីប្រកាសដំណឹងល្អ

**អត្ថបទទី១៖ អេសាយ ៦៦,១០-១៤**

ព្រះអម្ចាស់មានព្រះបន្ទូលថា៖ យើងនឹងឲ្យសេចក្តីសុខសាន្ត ហូរមកក្រុងនេះដូចទឹកទន្លេ យើងនឹងបង្ហូរធនធានដ៏រុងរឿងរបស់ប្រជាជាតិនានាចូលមកក្នុងក្រុងនេះ ដូចទឹកហូរប្រៀបមាត់ច្រាំង។ អស ៦៦,១២

**ដំណឹងល្អ៖ ម៉ាថាយ ១៨,១-៤**

ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា បើអ្នករាល់គ្នាមិនដូរចិត្តគំនិតឲ្យបានដូចក្មេងតូចៗទេ អ្នករាល់គ្នាមិនអាចចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខបានឡើយ។ មថ ១៨,៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាយប់ទី៩៥ដែលយើងអធិដ្ឋានសម្រាប់ការត្រាស់ហៅ ថ្ងៃទី០១ ខែតុលា ជាខួប ១០ឆ្នាំដែលខ្ញុំទទួលមុខងារជាអភិបាលពេញសិទ្ធិ នៅព្រះសហគមន៍ភូមិភាគភ្នំពេញ។ ថ្ងៃនេះ ជាថ្ងៃដែលយើងរំលឹកដល់សន្តីតេរេសានៃព្រះកុមារយេស៊ូ ដែលគាត់មានតួនាទីមួយពិសេសដូចបងស្រីកាម៉ែលទាំងអស់ គឺអធិដ្ឋានសម្រាប់បូជាចារ្យ។ តេរេសាពេលគាត់នៅក្មេង គាត់បានចូលអភិបូជារាល់ថ្ងៃជាមួយឪពុកម្តាយ គាត់ធ្លាប់សួរខ្លួនឯងជាច្រើនដងថា **មូលហេតុអ្វីបានជានៅក្នុងអារាមកាម៉ែលបងស្រីអធិដ្ឋានសម្រាប់បូជាចារ្យ?** គាត់គិតថាបូជាចារ្យជាមនុស្សពិសេស ជាសន្តនៅលើផែនដីនេះ បូជាចារ្យជាមនុស្សដែលដូចព្រះជាម្ចាស់ម្យ៉ាង ដូច្នេះហេតុអ្វីត្រូវការអធិដ្ឋានសម្រាប់បូជាចារ្យ។

នៅពេលតេរេសាមានអាយុ១៤ឆ្នាំ គាត់បានធ្វើដំណើរទៅទីក្រុងរ៉ូមជាមួយឪពុកនិងគ្រីស្តបរិស័ទនៅក្នុងព្រះវិហារគាត់ ដើម្បីជួបជាមួយសម្តេចប៉ាប។ នៅពេលនោះ មានលោកឪពុកដែលទទួលខុសត្រូវព្រះសហគមន៍គាត់ទៅដែរ ដោយបានធ្វើដំណើរជាមួយគ្នា២សប្តាហ៍។ ក្រោយមកគាត់បានសរសេរលិខិតមួយច្បាប់ថា “**ឥឡូវនេះខ្ញុំយល់ លោកឪពុកជាមនុស្សសាមញ្ញធម្មតា លោកមិនមែនជាអ្នកដ៏វិសុទ្ធ បរិសុទ្ធដូចព្រះជាម្ចាស់ទេ**”។ ពេលគាត់បានធ្វើដំណើរ២សប្តាហ៍ គាត់បានឃើញរបៀបរបស់លោកឪពុក ខឹងគេ ស្តីឲ្យគេ អស់កម្លាំង...។ លោកបូជាចារ្យជាមនុស្សសាមញ្ញធម្មតា ហើយការអធិដ្ឋានរបស់បងស្រីកាម៉ែលក៏ដូចជាការអធិដ្ឋានរបស់បងប្អូនទាំងអស់

សំខាន់ណាស់សម្រាប់លោកបូជាចារ្យ។ ជួនកាលយើងអស់កម្លាំងដែរ ប៉ុន្តែនៅពេលយើងដឹងថាមានបងប្អូនជាច្រើនបានអធិដ្ឋានសម្រាប់យើង ណែនាំឲ្យយើងមានកម្លាំងដើម្បីតស៊ូតទៅទៀត។

**ចំណុចទីមួយ** ជីវិតរបស់លោកអភិបាលក្តី របស់លោកបូជាចារ្យក្តី យើងអាចទៅមុខបានដោយសារយើងមានការអធិដ្ឋានដែលចេញពីគ្រីស្តបរិស័ទ ដែលចេញពីព្រះសហគមន៍ ដើម្បីឲ្យយើងមានកម្លាំងកាយកម្លាំងចិត្ត។ តេរេសាគាត់មានគំនិតច្រើននៅក្នុងជីវិតគាត់ ចង់ធ្វើជាបងស្រីផង ចង់ធ្វើជាសាសនាទូតផង ចង់ធ្វើគ្រីស្តទូតផង ចង់ធ្វើទាហានរបស់ព្រះជាម្ចាស់ផង ចង់ធ្វើជាបូជាចារ្យផង ប៉ុន្តែគាត់មិនអាចធ្វើទាំងអស់បានទេ។ នៅពេលគាត់ចូលអារាមកាម៉ែល មានថ្ងៃមួយគាត់សប្បាយចិត្តមែនទែន ប្រធានបងស្រីហៅគាត់ហើយប្រាប់បងស្រីតេរេសាថា "**ចាប់ពីថ្ងៃនេះតទៅខ្ញុំផ្ញើលោកឪពុកពីរនាក់ធ្វើជាកូនធម៌របស់បងស្រី សូមបងស្រីអធិដ្ឋានសម្រាប់លោកឪពុកទាំងពីរនាក់នោះផង**"។ លោកឪពុកម្នាក់ឈ្មោះ ប៉ែលល្សៃ នៅអាហ្វ្រិច និងម្នាក់ទៀតឈ្មោះ អូឡង់ ជាក្រុមសាសនាទូត MEP នៅប្រទេសចិន។ ថ្ងៃនោះ ធ្វើឲ្យតេរេសាសប្បាយចិត្តណាស់ គាត់បានសរសេរសំបុត្រជាច្រើនដើម្បីដឹកនាំលើកទឹកចិត្តទៅលោកឪពុកទាំងពីរនាក់។ គាត់ចង់ធ្វើជាបូជាចារ្យតែគាត់ជាស្រីមិនអាចធ្វើបាន តេរេសាគាត់យល់ថាបូជាចារ្យមានតួនាទីមួយពិសេសបំផុតគឺណែនាំឲ្យការសង្គ្រោះទៅដល់មនុស្សលោក ណែនាំឲ្យបងប្អូនឯទៀតៗទទួលជីវិតដ៏បរិបូណ៌ពីព្រះជាម្ចាស់។ នៅពេលនោះ តេរេសាគាត់យល់ថា "**ខ្ញុំធ្វើជាបូជាចារ្យមិនបាន ប៉ុន្តែខ្ញុំចូលតាមរយៈការអធិដ្ឋាន នៅក្នុងបេសកកម្មរបស់បូជាចារ្យទាំងឡាយ ដើម្បីណែនាំឲ្យជីវិតរបស់ព្រះជាម្ចាស់ផ្ទាល់ទៅដល់បងប្អូនឯទៀតៗ**"។ មានន័យថា គាត់បានចូលនៅក្នុងគម្រោងការនៃការសង្គ្រោះរបស់ព្រះជាម្ចាស់តាមរយៈការអធិដ្ឋាន និងជាពិសេសតាមរយៈលោកបូជាចារ្យទាំងពីរដែលគាត់បានទទួល។

**ចំណុចទីពីរ** នៅពេលខ្ញុំជាឧបដ្ឋាកបានចូលនៅក្នុងសំណាក់ធម៌មួយ ដែលដឹកនាំដោយលោកឪពុកម្នាក់បានជ្រើសរើសចំណងជើងថា "**បូជាចារ្យមានអំណរសប្បាយតែមួយគត់ គឺណែនាំឲ្យជីវិតដ៏បរិបូណ៌របស់ព្រះយេស៊ូទៅដល់បងប្អូនឯទៀតៗ**"។ នៅពេលនោះ ខ្ញុំបានស្តាប់ដើម្បីធ្វើជាទស្សនៈ ២០ឆ្នាំក្រោយមក ១០ឆ្នាំជាបូជាចារ្យ ១០ឆ្នាំជាអភិបាល ខ្ញុំបានឃើញផ្ទាល់មានបងប្អូនប៉ុន្មាននាក់ ដែលចេញពីការអស់សង្ឃឹមចូលនៅក្នុងសេចក្តីសង្ឃឹមសាជាថ្មីដោយសារព្រះសហគមន៍ ដោយសារគេបានជួបជាមួយព្រះយេស៊ូ ដោយបានកែប្រែចិត្តគំនិត។ គេបានជួបជាមួយបងប្អូនដែលជាគ្រីស្តបរិស័ទ ដែលជាគ្រួសារថ្មីមួយចេះលើកទឹកចិត្ត ដែលបានធ្វើដំណើរជាមួយគេ។ តាមរយៈជីវិតយើងជាបូជាចារ្យ យើងអាចណែនាំជីវិតរបស់ព្រះអង្គដល់ព្រះសហគមន៍ផង ដល់បងប្អូនឯទៀតៗផងរួមគ្នានៅក្នុងគ្រួសារតែមួយ។

តួនាទីរបស់លោកអភិបាល គឺអប់រំ ជាមូលហេតុមានមួកដែលជាសញ្ញាសម្គាល់នៃការអប់រំ ណែនាំ និងមានដំបងដែលជាសញ្ញានៃគ្រូគង្វាលដើម្បីដឹកនាំ ធ្វើដំណើរជាមួយបងប្អូន ដើម្បីលីឈើឆ្កាងផ្ទាល់ខ្លួននិងជួយលីឈើឆ្កាងបងប្អូនដែរ។ តួនាទីរបស់គ្រូគង្វាល ជួនកាលយើងនៅមុខ ជួនកាលយើងនៅកណ្តាល ជួនកាលយើងនៅក្រោយ ពេលយើងនៅមុខជួនកាលកូនចៅដើរមិនទាន់ ណែនាំឲ្យយើងត្រូវការនៅកណ្តាលដើម្បីយល់ខ្លឹមសារនៃជីវិត ហើយពេលខ្លះយើងត្រូវការនៅក្រោយដើម្បីរុញឲ្យទៅមុខ កុំឲ្យអ្នកនៅក្រោយដួលហើយក្រោកឡើងមិនបានដោយសារគ្មានអ្នកណាដែលមើល។ យើងធ្វើដំណើរជាមួយគ្នា ដើម្បីណែនាំឲ្យព្រះសហគមន៍របស់យើងទៅជាអង្គតែមួយ ព្រះសហគមន៍របស់យើងដែលមានស្ថានភាពខុសៗគ្នា ធ្វើដំណើរជាមួយគ្នាបាន។ ក្នុងភូមិភាគភ្នំពេញយើងមានប្រាំបួនមណ្ឌលសកម្មភាព មានទីក្រុងផង មានជនបទផង មានទន្លេផង មានព្រះសហគមន៍ចាស់ផង មានព្រះសហគមន៍ថ្មីផង យើងមានសាសនាទូតច្រើន ទាំងបូជាចារ្យ ទាំងបងប្រុស ទាំងបងស្រី ទាំងអស់ជាង២៥ប្រទេស។ នៅក្នុងរបៀបខុសៗគ្នាទាំងអស់ ជាតួនាទីលោកអភិបាលដើម្បីធ្វើដំណើរជាមួយគ្នាបាន នៅពេលយើងជួបជុំគ្នាមួយឆ្នាំម្តងក្នុងបុណ្យព្រះយេស៊ូសម្តែងព្រះអង្គឲ្យមនុស្សលោកឃើញ ណែនាំឲ្យយើងឃើញថានេះជាមហាគ្រួសារតែមួយដែលធ្វើដំណើរជាមួយគ្នាបាន។ តាមរយៈការិយាល័យភូមិភាគនីមួយៗ ពេលយើងមានមហាសន្និបាត ពេលយើងមានសិក្ខាសាលា ពេលយើងជួបជុំគ្នាយើងឃើញជាក់ស្តែង យើងជាមនុស្សខុសៗគ្នាប៉ុន្តែយើងធ្វើដំណើរជាមួយគ្នាបាន។

**ចំណុចទីបី** បង្កើតគ្រួសារមួយដែលចេះស្រឡាញ់គ្នាទៅវិញទៅមក គ្រួសារមួយដែលចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក គ្រួសារមួយដែលចេះសម្រុះសម្រួលគ្នាដោយយល់ចិត្តគ្នា ជាពិសេសគ្រួសារគ្រីស្តបរិស័ទដែលចេះប្រកាសដំណឹងល្អចេញពីកន្លែងផ្ទាល់ខ្លួន។ របងណែនាំឲ្យយើងបិទទ្វារដើម្បីកក់ក្តៅផ្ទាល់ខ្លួន កូវីដ១៩សព្វថ្ងៃនៅក្នុងអាស៊ីអាគ្នេយ៍បានបិទព្រំដែនអស់ហើយ។ អ្នកផ្សព្វផ្សាយព័ត៌មាន សព្វថ្ងៃកំពុងបង្កើតបរិយាកាសភ័យខ្លាចនៅក្នុងពិភពលោក ប្រទេសនៅអឺរ៉ុបគេបានបើកទ្វារព្រំដែននៅក្នុងទ្វីបអឺរ៉ុប ដើម្បីឲ្យមានចរន្តសេដ្ឋកិច្ចដើរវិញ។ ព្រះសហគមន៍របស់យើង ត្រូវការធ្វើប្រយ័ត្នមែនទែនកុំឲ្យយើងកក់ក្តៅតែគ្នាយើង ឲ្យយើងបើកទ្វារដើម្បីប្រកាសដំណឹងល្អ។ ១០ឆ្នាំជាលោកអភិបាល ខ្ញុំយល់ថាប្រកាសដំណឹងល្អមិនមែនតែថាយើងត្រូវការធ្វើពិធីជ្រមុជទឹកប៉ុន្មានៗ យើងត្រូវការណែនាំឲ្យបងប្អូនមួយចំនួនទៅជាគ្រីស្តបរិស័ទ ប៉ុន្តែអ្វីដែលសំខាន់ក្នុងការប្រកាសដំណឹងល្អ គឺបង្កើតក្រុមគ្រួសារមួយនៅកន្លែងរបស់យើង។ ព្រះសហគមន៍ធ្វើដំណើរជាមួយប្រជាជនធម្មតា តាមរយៈការសិក្សា តាមរយៈការអភិវឌ្ឍជនបទ តាមរយៈកសិកម្ម តាមរយៈជីវិតធម្មតាជាមួយឪពុកម្តាយ ជាមួយអាជ្ញាធរដែនដី ជាមួយ

អន្តរសាសនា។ មិនមែនន័យថា យើងត្រូវការណែនាំបងប្អូនទាំងអស់ទៅជាគ្រីស្តបរិស័ទទេ ការប្រកាសដំណឹងល្អណែនាំឲ្យកន្លែងដែលព្រះសហគមន៍នៅ អាចបង្កើតសហគមន៍នៃជីវិតដែលចេះរួបរួមគ្នា ចេះគោរពគ្នា ចេះជួយគ្នាពេលមានបញ្ហា។ នេះជារបៀបដែលយើងអាចបង្កើតព្រះសហគមន៍ដ៏ពិតប្រាកដ ជារបៀបដែលយើងអាចប្រកាសដំណឹងល្អដ៏ពិតប្រាកដ ណែនាំឲ្យយើងរួមរស់នៅលើដីដែលយើងនៅ ជាមួយបងប្អូនទាំងអស់ដែលមាននៅជុំវិញ។ អ្នកតូចតាចក្តី អ្នកក្រីក្រក្តី អ្នកមានក្តី អាជ្ញាធរដែនដីក្តី យើងធ្វើដំណើរជាមួយគ្នាជាក្រុមគ្រួសារតែមួយ នេះជារបៀបការប្រកាសដំណឹងដ៏ជោគជ័យ។ ខ្ញុំជឿថា នៅក្នុងនោះព្រះជាម្ចាស់មានវត្តមានយ៉ាងពិតប្រាកដ ណែនាំឲ្យយើងទៅមុខតទៅទៀត។

សន្តីតេរេសា បានដាក់ខ្លួនដើម្បីរួមរស់តាមរបៀបព្រះយេស៊ូ សន្តីតេរេសាជាអ្នកបម្រើរបស់ព្រះជាម្ចាស់ដ៏ពិតប្រាកដ ណែនាំឲ្យយើងយល់ថា ប្រសិនបើយើងឥតមានចិត្តគំនិតដូចកូនក្មេងម្នាក់ យើងមិនអាចចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់បានទេ។ ថ្ងៃនេះ ខ្ញុំសូមអធិដ្ឋានសម្រាប់ខ្ញុំផ្ទាល់ខ្លួនផង សម្រាប់បូជាចារ្យផង សម្រាប់បងប្រុសបងស្រីផង សម្រាប់គ្រីស្តបរិស័ទយើងទាំងអស់ ឲ្យយើងកែប្រែចិត្តគំនិតថែមទៀត ឲ្យយើងមានគំនិតដូចកូនក្មេងម្នាក់ ដើម្បីចូលនៅក្នុងជីវិតរបស់ព្រះជាម្ចាស់ដ៏ពិតប្រាកដ។ ដោយនឹកឃើញព្រះជាម្ចាស់ដែលមានឫទ្ធានុភាពសព្វប្រការបានចាប់កំណើតជាមនុស្ស ដោយដាក់ខ្លួនទាបបំផុតដើម្បីធ្វើដំណើរជាមួយ និងដើម្បីណែនាំឲ្យយើងចូលនៅក្នុងជីវិតរបស់ព្រះជាម្ចាស់ផ្ទាល់បាន។ យើងអធិដ្ឋាន ដើម្បីឲ្យយើងរួមគ្នាយើងចូលរួមនៅក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់ភូមិភាគភ្នំពេញ សម្រាប់ប្រទេសកម្ពុជាយើង សម្រាប់ពិភពលោកយើង។ អាម៉ែន៕